ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

បេឡាជាតិរបបសន្តិសុខសង្គម

លេខ :...០២/........ប.ស.ស
១៩

# សេចក្តីជូនដំណឹង
## ស្តីពី
## ការផ្តល់ប្រាក់តាវកាលិកផ្នែកហានិភ័យការងារ និងតាវកាលិកផ្នែកថែទាំសុខភាព ជូនកម្មករនិយោជិតតាមឈ្មោះគណនី នៅធនាគារអេស៊ីលីដា ភី អិលស៊ី

បេឡាជាតិរបបសន្តិសុខសង្គម (បសស) សូមជម្រាបជូនដំណឹងដល់កម្មករ និយោជិត និងនិយោជកជាម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ឲ្យបានជ្រាបថា ដើម្បីបង្កើតភាពងាយស្រួលការផ្តល់ប្រាក់តាវកាលិកនេះឲ្យកាន់តែឆាប់រហ័ស និងចំណេញពេលវេលា និងពុំចាំបាច់ធ្វើដំណើរមកទទួលសេចក្តីសម្រេចពីទីតាំងប.ស.ស រាជធានី ខេត្តដោយផ្ទាល់ បេឡាជាតិរបបសន្តិសុខសង្គម បន្ថែមរបៀបផ្តល់ប្រាក់នេះតាម**ឈ្មោះនិងលេខគណនីផ្ទាល់**របស់សមាជិកនៅធនាគារអេស៊ីលីដា ភីអិលស៊ី ដោយភ្ជាប់មានជាមួយក្នុងឯកសារណាមួយដូចខាងក្រោម:

-ប័ណ្ណព័ត៌មានគណនី

-សៀវភៅគណនី ឬ

-ឯកសារផ្សេងៗ(មានឈ្មោះគណនី)របស់ខ្លួនមកជាមួយ។

បេឡាជាតិរបបសន្តិសុខសង្គមសង្ឃឹមថា កម្មករ និយោជិត និងនិយោជក ជាម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ ចូលរួមអនុវត្តតាមសេចក្តីជូនដំណឹងនេះ និងជួយផ្សព្វផ្សាយឲ្យបាន ទូលំទូលាយជូនដល់កម្មករនិយោជិតរបស់ខ្លួន។

ថ្ងៃ...........ខែ..........ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី.......ខែ.......ឆ្នាំ២០១៩